# ដាក់ពាក្យសុំអាជ្ញាប័ណ្ណបូមទឹកនៅភូមិភាគ Adelaide River នៃភូមិបាលគ្រប់គ្រងទឹកជនបទនៃក្រុងដាវីន (71M)

ទម្រង់នេះប្រើសម្រាប់តែការដាក់ពាក្យសុំយកអាជ្ញាប័ណ្ណបូមទឹក នៅភូមិភាគ Adelaide River នៃភូមិបាលគ្រប់គ្រងទឹកជនបទនៃក្រុងដាវីន ដែលការប្រើប្រាស់ទឹកកន្លងមកត្រូវបានលើកលែងពីតម្រូវការឲ្យមានអាជ្ញា ប័ណ្ណដូចមានចែងក្នុងលិខិតគតិយុត្តិ(ច្បាប់)លេខ14A និងលេខ14AB ។

ឱកាសក្នុងការដាក់ពាក្យសុំអាជ្ញាប័ណ្ណ ដោយប្រើទម្រង់ពាក្យសុំនេះ មានផ្តល់ជូនចំពោះ៖

1. **<u>អតីតភូមិបាលគ្រប់គ្រងទឹកជនបទនៃក្រុងដាវីន</u> នឹងអស់សុពលភាពនៅថ្ងៃទី31 ខែកក្កដា ឆ្នាំ2025** យោងតាមលិខិតគតិយុត្តិ(ច្បាប់)លេខ14A(1)(e)។
2. **<u>ភូមិភាគ Adelaide River នៃភូមិបាលគ្រប់គ្រងទឹកជនបទនៃក្រុងដាវីន</u> នឹងអស់សុពលភាពនៅថ្ងៃទី30 ខែកក្កដា ឆ្នាំ2026** យោងតាមលិខិតគតិយុត្តិ(ច្បាប់)លេខ14AB(1)(e)។

## សេចក្តីណែនាំ និងការទទួលខុសត្រូវរបស់អ្នកដាក់ពាក្យសុំ

ដើម្បីធានាប្រសិទ្ធិភាពនៃការពិនិត្យដំណើរការពាក្យស្នើសុំ និងការវាយតម្លៃ៖

*1.* សូមឆ្លើយតបគ្រប់សំណួរទាំងអស់ ដោយភ្ជាប់មកជាមួយនូវឯកសារនានាត្រង់ចំណុចណាដែលតម្រូវឲ្យមានការបញ្ជាក់។

2. សូមធ្វើការត្រួតពិនិត្យឡើងវិញនូវពាក្យស្នើសុំនេះក្រោយពេលបំពេញចប់រួចរាល់ព្រមជាមួយនឹងឯកសារភ្ជាប់នានា ដើម្បីធានាឱ្យបានថាការបំពេញពាក្យសុំក៏ដូចជាឯកសារភ្ជាប់ទាំងឡាយត្រូវសមស្របតាមការស្នើសុំ ហើយបានផ្តល់សព្វគ្រប់នូវព័ត៌មានពាក់ព័ន្ធ និងត្រឹមត្រូវច្បាស់ លាស់។

3. សូមប្រើបញ្ជីផ្ទៀងផ្ទាត់ដែលមាននៅទំព័រដើម្បីធានានូវការត្រួតពិនិត្យឡើងវិញថាបានបំពេញតាមលក្ខខណ្ឌនានាសព្វគ្រប់។

ប្រសិនបើលោកអ្នក មានចម្ងល់ ឬសំណួរ សូមទាក់ទងមកអ៊ីម៉ែល water.licensing@nt.gov.au ឬទូរសព្ទលេខ: (08) 8999 4455។

## របៀបដាក់ពាក្យស្នើសុំ

សូមផ្ញើពាក្យសុំដែលបានបំពេញរួចមកអ៊ីម៉ែល water.licensing@nt.gov.au

## អត្ថន័យនៃសញ្ញាសម្គាល់ ឬicons មួយចំនួននៅក្នុងទម្រង់ពាក្យស្នើសុំនេះ

ⓘ សំខាន់ដើម្បីជួយលោកអ្នកក្នុងការបំពេញពាក្យស្នើសុំនេះ។

✎ បង្ហាញពីការណែនាំក្នុងការបំពេញពាក្យស្នើសុំនេះ។

🗎 បង្ហាញប្រាប់ថា ត្រូវផ្តល់ឯកសារណាមួយ ឬភស្តុតាងគាំទ្រ ដែលត្រូវភ្ជាប់ជាមួយនឹងពាក្យស្នើសុំនេះ។

🕮 បង្ហាញប្រាប់ថា មានការពន្យល់ពីនិយមន័យ នៅផ្នែកខាងក្រោមនៃទំព័រ។

## ការជូនដំណឹងស្តីពីការប្រមូលព័ត៌មាន និងការរក្សាឯកជនភាព

ព័ត៌មានពិស្តារដែលលោកអ្នកបានផ្តល់នៅក្នុងពាក្យស្នើសុំនេះ អាចនឹងត្រូវបានយកទៅបោះពុម្ពផ្សាយនៅក្នុងគេហទំព័រអាជ្ញាប័ណ្ណបូមទឹកនៃដែនដីខាងជើងប្រទេសអូស្ត្រាលី។ ប្រសិនបើលោកអ្នកមានសំណួរ អំពីការគ្រប់គ្រងព័ត៌មានផ្ទាល់ខ្លួនលោកអ្នក ឬក៏ចង់ចូលមើលព័ត៌មានផ្ទាល់ខ្លួនរបស់លោកអ្នកនោះ លោកអ្នកអាចទំនាក់ទំនងទៅ Water Resources Division (នាយកដ្ឋានធនធានទឹក)។ រដ្ឋាភិបាលដែនដីខាងជើងអនុវត្តតាម គោលការណ៍ស្តីពីព័ត៌មានឯកជនបុគ្គល ដែលមានចែងក្នុង *ច្បាប់ស្តីពីព័ត៌មានឆ្នាំ2002* (🕮)។ ចំពោះព័ត៌មានបន្ថែម សូមចូលមើល គោលនយោបាយស្តីពីឯកជនភាព របស់យើង(🕮)។

---

🕮 https://nt.gov.au/page/copyright-disclaimer-and-privacy
🕮 https://nt.gov.au/page/copyright-disclaimer-and-privacy

## អ្នកមានសិទ្ធដាក់ពាក្យស្នើសុំ

ⓘ អ្នកចាំបាច់ត្រូវកំណត់នូវទីតាំងដីដែលអ្នកដាក់ពាក្យស្នើសុំ ដោយប្រើផែនទីខាងក្រោម។

- (black outline) អតីតភូមិបាលគ្រប់គ្រងទឹកជនបទនៃក្រុងដាវិន – *សូមមើលទៅសំណួរ* 1A។
- (blue outline) ភូមិភាគ Adelaide River នៃភូមិបាលគ្រប់គ្រងទឹកជនបទនៃក្រុងដាវិន – *មើលទៅសំណួរ* 1B។

ប្រសិនបើអ្នកមិនអាចឆ្លើយបានថា “បាទ/ចាស់” ទៅនឹងសំណួរទាំងអស់នៅក្នុងផ្នែក1A ឬ 1B ទេ, អ្នកមិនអាចប្រើពាក្យស្នើសុំនេះបានទេ។

សូមទាក់ទង Water Regulation (អាជ្ញាធរទឹក) តាមលេខទូរសព្ទ (08) 8999 4455
បើសិនជាអ្នកចង់ពិភាក្សាពីទីតាំងដីរបស់អ្នក
ឬលក្ខខណ្ឌពាក់ព័ន្ធនឹងសិទ្ធិក្នុងការដាក់ពាក្យសុំអាជ្ញាប័ណ្ណនៅសំណួរ 1។



## 1. តើអ្នកមានសិទ្ធិក្នុងការដាក់ពាក្យសុំអាជ្ញាប័ណ្ណបូមទឹកក្រោមដី សម្រាប់សកម្មភាពលើកលែងដែរឬទេ?

### 1A. អតីតភូមិបាលគ្រប់គ្រងទឹកជនបទនៃក្រុងដារវិន

| | | |
|---|---|---|
| **ការស្នើសុំអាជ្ញាប័ណ្ណនៅអតីតភូមិបាលគ្រប់គ្រងទឹកជនបទនៃក្រុងដារវិន** | ☐ បាទ/ចាស៎ | ☐ ទេ |
| **ក្នុងអំឡុងពេលពីថ្ងៃទី6 ខែកក្កដា ឆ្នាំ2015 ដល់ថ្ងៃទី5 ខែកក្កដា ឆ្នាំ2016 មានការយកទឹកជាប្រចាំតាមទម្លាប់ដោយ (🕮) ខួងចេញពីទីតាំងដី ដែលមានអាជីវកម្មកំពុងដំណើរការ (🕮) ដោយអាស្រ័យលើទឹកក្រោមដីនៅទីតាំងដីនោះ។** | ☐ បាទ/ចាស៎ | ☐ ទេ |
| **ក្នុងអំឡុងពេលពីថ្ងៃទី6 ខែកក្កដា ឆ្នាំ2016 មកទល់នឹងពេលដាក់ពាក្យស្នើសុំនេះ អ្នកបានបន្តធ្វើជាប្រចាំតាមទម្លាប់ដោយខួងយកទឹកក្រោមដីនៅទីតាំងដី ដែលមានអាជីវកម្មកំពុងដំណើរការ។** | ☐ បាទ/ចាស៎ | ☐ ទេ |
| **អាជីវកម្មដែលកំពុងដំណើរការមិនមែនជាសកម្មភាពរុករករ៉ែ ឬប្រេងឥន្ទនៈទេ។**<br>ប្រសិនបើអ្នកឆ្លើយថា ទេ ចំពោះសំណួរនេះ អ្នកមិនអាចបំពេញទម្រង់ពាក្យសុំនេះទេ។ យោង *ទម្រង់លេខ 45/60 ពាក្យសុំប្រើប្រាស់ទឹក* | ☐ បាទ/ចាស៎ | ☐ ទេ |

### 1B. ភូមិបាលគ្រប់គ្រងទឹកជនបទនៃក្រុងដារវិន ភូមិភាគ Adelaide River

| | | |
|---|---|---|
| **ការស្នើសុំអាជ្ញាប័ណ្ណនឹងធ្វើឡើងសំដៅទៅលើភូមិភាគ Adelaide River នៃភូមិបាលគ្រប់គ្រងទឹកជនបទនៃក្រុងដារវិន** | ☐ បាទ/ចាស៎ | ☐ ទេ |
| **ក្នុងអំឡុងពេលពីថ្ងៃទី1 ខែកក្កដា ឆ្នាំ2023 ដល់ថ្ងៃទី30 ខែមិថុនា ឆ្នាំ2024 មានការយកទឹកជាប្រចាំតាមទម្លាប់ដោយ (🕮) ខួងចេញពីទីតាំងដី ដែលមានអាជីវកម្មកំពុងដំណើរការ (🕮) ដោយពឹងអាស្រ័យលើទឹកក្រោមដីនៅទីតាំងដីនោះ។** | ☐ បាទ/ចាស៎ | ☐ ទេ |
| **ក្នុងអំឡុងពេលពីថ្ងៃទី1 ខែកក្កដា ឆ្នាំ2024 ដល់ពេលដាក់ពាក្យស្នើសុំនេះ អ្នកបានបន្តធ្វើជាប្រចាំតាមទម្លាប់ដោយខួងយកទឹកក្រោមដីនៅទីតាំងដីនេះ ដែលមានអាជីវកម្មកំពុងដំណើរការ។** | ☐ បាទ/ចាស៎ | ☐ ទេ |
| **អាជីវកម្មដែលកំពុងដំណើរការមិនមែនជាសកម្មភាពរុករករ៉ែ ឬប្រេងឥន្ទនៈទេ។**<br>ប្រសិនបើអ្នកឆ្លើយថា ទេ ចំពោះសំណួរនេះ អ្នកមិនអាចបំពេញទម្រង់ពាក្យសុំនេះទេ។ យោង *ទម្រង់លេខ 45/60 ពាក្យសុំប្រើប្រាស់ទឹក*[1] | ☐ បាទ/ចាស៎ | ☐ ទេ |

🕮 **ដោយធ្វើឡើងជាប្រចាំ** សំដៅទៅលើការយកទឹកដោយខួងយកជាធម្មតា ជាផ្នែកមួយនៃដំណើរការអាជីវកម្ម នៅក្នុងលក្ខណៈដែលអាចព្យាករទុកបាន។ ឧទាហរណ៍៖ សកម្មភាពខួងយកទឹក អាចរួមបញ្ចូលនូវសកម្មភាពប្រចាំឆ្នាំក្នុងការស្រោចស្រពដំណាំជាទៀងទាត់នៅអំឡុងរដូវប្រាំង ទោះបីជានៅរដូវភ្លៀងមិនមានការស្រោចស្រពក្តី។

🕮 **សកម្មភាពធ្វើពាណិជ្ជកម្ម** យោងទៅលើអាជីវកម្ម ឬសហគ្រាសដែលធ្វើសកម្មភាពដើម្បីរកប្រាក់ចំណេញ។ សកម្មភាពពាណិជ្ជកម្មអាចធ្វើឡើងជាលក្ខណៈបុគ្គលឯកជន, ភាពជាដៃគូសហការ ឬជាសាជីវកម្ម។

## ព័ត៌មានពិស្តាររបស់អ្នកដាក់ពាក្យសុំ

**2. តើនរណាជាអ្នកដាក់ពាក្យសុំអាជ្ញាប័ណ្ណនេះ?**

ⓘ ឈ្មោះអ្នកដាក់ពាក្យសុំ និងឈ្មោះអ្នកទទួលអាជ្ញាប័ណ្ណ គឺជាឈ្មោះតែមួយនៅលើអាជ្ញាប័ណ្ណ។

✎ សូមផ្តល់ព័ត៌មានពិស្តារនៃបុគ្គល ឬស្ថាប័នស្របច្បាប់ដែលសុំអាជ្ញាប័ណ្ណបូមទឹក។ ប្រសិនបើសុំអាជ្ញាប័ណ្ណសម្រាប់អ្នកដាក់ពាក្យសុំរួមគ្នា សូមផ្តល់ព័ត៌មានពិស្តាររបស់អ្នកដាក់ពាក្យទាំងអស់។

| **ឈ្មោះអ្នកដាក់ពាក្យ:** | |
|---|---|

☐ **បុគ្គលអ្នកដាក់ពាក្យសុំ (រូបវន្តបុគ្គល)**

☐ **អ្នកដាក់ពាក្យសុំរួមគ្នា (សហកម្មសិទ្ធ)**

☐ **ក្រុមហ៊ុន/អាជីវកម្ម** (សូមបំពេញខាងក្រោម)

☐ បានចុះបញ្ជីការអាជីវកម្ម

លេខចុះបញ្ជីការអាជីវកម្មអូស្ត្រាលី (ABN):_______________________

🗎ភ្ជាប់មកជាមួយនូវសម្រង់ឈ្មោះអាជីវកម្មបច្ចុប្បន្នមួយច្បាប់

☐ ក្រុមហ៊ុន

លេខចុះបញ្ជីការក្រុមហ៊ុនអូស្ត្រាលី (ACN):_______________________

🗎 ភ្ជាប់មកជាមួយនូវសម្រង់ក្រុមហ៊ុនបច្ចុប្បន្នមួយច្បាប់ពី ASIC

☐ **មិនបានចុះបញ្ជីការអាជីវកម្ម ឬក្រុមហ៊ុន?** 🗎 សូមផ្តល់ព័ត៌មានអំណះអំណាងដែលថាសកម្មភាពរបស់អ្នកមានលក្ខណៈពាណិជ្ជកម្ម។

.................................................................................................................................

.................................................................................................................................

**3. តើអ្នកណាជាអ្នកទំនាក់ទំនងសម្រាប់ពាក្យស្នើសុំនេះ?**

✎ សូមផ្តល់ព័ត៌មានពិស្តារសម្រាប់អ្នកធ្វើការទំនាក់ទំនងទី១ និងសម្រាប់អ្នកធ្វើការទំនាក់ទំនង២

| | **ព័ត៌មានសម្រាប់អ្នកទំនាក់ទំនងទី១** | **ព័ត៌មានសម្រាប់អ្នកទំនាក់ទំនងទី២** |
|---|---|---|
| **ឈ្មោះពេញ:**<br>**(គោត្តនាម និងនាម)** | | |
| **អាសយដ្ឋានទំនាក់ទំនងតាមប្រៃសណីយ៍:** | | |
| **លេខទូរសព្ទទំនាក់ទំនង:** | | |
| **អាសយដ្ឋានអ៊ីម៉ែល:**<br>ⓘ<br>ការប្រាស្រ័យទាក់ទងនឹងផ្ញើទៅកាន់អ៊ីម៉ែលនេះ | | |

## ព័ត៌មានអំពីទីតាំងដី

| 4. តើអាសយដ្ឋានទីតាំងដីធ្វើសកម្មភាពពាណិជ្ជកម្ម និងខួងបូមយកទឹក ឋិតនៅទីណា? | | | |
|---|---|---|---|
| **អាសយដ្ឋានទីតាំង:** (លេខដីឬផ្ទះ/ឈ្មោះផ្លូវ/តំបន់) | | | |
| **លេខសម្គាល់ទីតាំងដី:** | | **ទីតាំង/Hundred** | |

| 5. តើខាងក្រោមនេះ ឃ្លាមួយណាដែលត្រឹមត្រូវជាងគេ សម្រាប់បង្ហាញពីសិទ្ធរបស់អ្នកក្នុងការប្រើប្រាស់ដីខាងលើនេះ? | | |
|---|---|---|
| **ខ្ញុំគឺជា:** | គូស (✓) | **តម្រូវឲ្យមានភស្តុតាង និងឯកសារភ្ជាប់** |
| ម្ចាស់ដី | ☒ | ច្បាប់ចម្លងនៃប័ណ្ណសម្គាល់ម្ចាស់កម្មសិទ្ធអចលនវត្ថុ |
| អ្នកដែលបានទទួលសិទ្ធកាន់កាប់ដី (📖) | ☐ | ច្បាប់ចម្លងនៃលិខិតប្រគល់សិទ្ធ ឬលិខិតអនុញ្ញាតជាលាយលក្ខណ៍អក្សរ និងលក្ខខណ្ឌនៃការអនុញ្ញាត |
| ឯកសារផ្សេងៗទៀត សូមរៀបរាប់បញ្ជាក់:<br>................................................<br>................................................ | ☐ | ឯកសារអំណះអំណាងឬភស្តុតាងពាក់ព័ន្ធនានា:<br>................................................<br>................................................ |

## សកម្មភាពពាណិជ្ជកម្មទាក់ទងនឹងការប្រើប្រាស់ទឹកក្រោមដី

**6. តើប្រភេទសកម្មភាពពាណិជ្ជកម្មអ្វីដែលកំពុងប្រព្រឹត្តទៅនៅលើដីនោះ?**

ចូរផ្តល់ព័ត៌មានពិស្តារនៃអាជីវកម្ម ឬសកម្មភាពនានាដែលដំណើរការជាផ្នែកនៃការធ្វើអាជីវកម្ម។ សកម្មភាពទាំងនេះអាចរួមទាំងការរៀបរាប់ជាសង្ខេបអំពីអាជីវកម្ម, ការប៉ាន់ប្រមាណទំហំដីដែលប្រើសម្រាប់ធ្វើអាជីវកម្ម, ប្រភេទនៃដំណាំ, ចំនួនអ្នកធ្វើការ និងការប៉ាន់ប្រមាណពីចំនួនទឹកប្រើប្រាស់ប្រចាំឆ្នាំ។ ប្រសិនបើសកម្មភាពពាណិជ្ជកម្មនេះបានធ្វើច្រើនឆ្នាំមកហើយ ឬក៏អ្នកមានផែនការអភិវឌ្ឍនាពេលអនាគត សូមបញ្ចូលព័ត៌មានពិស្តារនៅតាមដំណាក់កាលនីមួយៗនៅក្នុងដំណើរការអភិវឌ្ឍអាជីវកម្ម។ ប្រសិនបើអ្នកមិនច្បាស់អំពីកាលបរិច្ឆេទជាក់ស្តែង សូមផ្តល់ការប៉ាន់ស្មាននូវកាលបរិច្ឆេទណាមួយក៏បាន។

🗎 ចូរផ្តល់ភស្តុតាងបញ្ជាក់ពីសកម្មភាពពាណិជ្ជកម្មដែលកំពុងដំណើរការ និងផែនទីពិស្តារនៃដី ដែលកំណត់ពីទំហំនៃការប្រើសម្រាប់សកម្មភាពពាណិជ្ជកម្ម, អណ្តូងខួងបូមទឹកប្រើប្រាស់ជាលក្ខណៈគ្រួសារ ឬអណ្តូងខួងដែលមាននាពេលបច្ចុប្បន្ន។ ឧទាហរណ៍ រួមទាំងរូបថតទាំងឡាយដែលបង្ហាញពីការប្រើប្រាស់ដីក៏ដូចជាការកំណត់សម្គាល់ប្រភេទដំណាំនានា, ព័ត៌មានអំពីដំណាំប្រចាំឆ្នាំ, ការដំឡើង ឬកិច្ចប្រតិបត្តិការហេដ្ឋារចនាសម្ព័ន្ធ។

................................................................................................
................................................................................................
................................................................................................
................................................................................................
................................................................................................
................................................................................................
................................................................................................
................................................................................................

📖 **អ្នកដែលបានទទួលសិទ្ធកាន់កាប់ដី** រួមបញ្ចូលទាំង អ្នកជួល, ភតិកៈ ឬអ្នកជួលបន្ត

ពាក្យស្នើសុំអាជ្ញាប័ណ្ណបូមទឹក នៅភូមិភាគ Adelaide River នៃភូមិបាលគ្រប់គ្រងទឹកជនបទនៃក្រុងដាវីន (71M)

## ការប្រើប្រាស់ទឹកក្រោមដី និងហេដ្ឋារចនាសម្ព័ន្ធក្នុងការបូមយកទឹកមកប្រើ

**7. ចូរបំពេញតារាងជាមួយនឹងការប៉ាន់ប្រមាណនៃបរិមាណទឹកដែលប្រើជា មេហ្គាលីត្រ (ML) ក្នុងមួយខែសម្រាប់ឆ្នាំនីមួយៗ។**

ប្រសិនបើអណ្តូងខួងទឹកមិនបានចុះបញ្ជី, សូមផ្តល់ទីតាំង GPS coordinates នៃអណ្តូង។

ថត និងចម្លង តារាងនេះសម្រាប់ចំណុចខួងយកទឹកនីមួយៗ។

| | | | | | |
|---|---|---|---|---|---|
| **កន្លែងដែលខួងយកទឹក:** (សូមផ្តល់លេខចុះបញ្ជី[RN]នៃអណ្តូង) | | **ទីតាំង GPS coordinates នៃអណ្តូង:** | **រយៈទទឹង:** | | |
| | | | **រយៈបណ្តោយ:** | | |

| | | | | | | |
|---|---|---|---|---|---|---|
| **ព័ត៌មានពីនាឡិការវាស់ទឹក** (បើមានដាក់) : | **ម៉ាក:** | | **ម៉ូដែល:** | | **លេខសេរី:** | |
| | **ឯកត្តានៃការវាស់វែង:** | | **អំណាន:** | | | |

| ឆ្នាំ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 20..... | | | | | | | | | | | | | |
| 20..... | | | | | | | | | | | | | |
| 20..... | | | | | | | | | | | | | |
| 20..... | | | | | | | | | | | | | |
| 20..... | | | | | | | | | | | | | |
| 20..... | | | | | | | | | | | | | |
| 20..... | | | | | | | | | | | | | |
| 20..... | | | | | | | | | | | | | |
| 20..... | | | | | | | | | | | | | |

# ការទទួលយល់ព្រម

## 8. ការចុះបញ្ជីការសាធារណៈ និងព័ត៌មានសម្ងាត់នៃពាណិជ្ជកម្ម

ⓘ យោងតាមជំពូក 95 នៃច្បាប់ អធិការធនធានទឹក ត្រូវរក្សាទុកបញ្ជីអាជ្ញាប័ណ្ណបូមទឹក។ បញ្ជីត្រូវបង្ហាញជាសាធារណៈនៅលើគេហទំព័រក្រសួង និងត្រូវមាន៖

- និងអាសយដ្ឋាននៃម្ចាស់អាជ្ញាប័ណ្ណ
- កាលបរិច្ឆេទផុតសុពលភាពនៃអាជ្ញាប័ណ្ណ
- ទីតាំងដីដែលកំពុងបូមយកទឹក
- អតិបរមានៃបរិមាណទឹកដែលអាចបូមយកប្រចាំឆ្នាំ
- ប្រភពនៃទឹកដែលអាចបូមយកមកប្រើបាន។

អធិការធនធានទឹក នឹងថតចម្លងពាក្យស្នើសុំនេះ ឯកសារភ្ជាប់នានា និងអាជ្ញាប័ណ្ណផ្ដល់ជូន បោះផ្សាយជាសាធារណៈនៅលើគេហទំព័ររបស់ក្រសួងផងដែរ។ អធិការធនធានទឹក មានសិទ្ធអំណាចក្នុងការមិនបញ្ចេញនូវព័ត៌មានមួយចំនួន ប្រសិនបើព័ត៌មានទាំងនោះមានលក្ខណៈជាព័ត៌មានសម្ងាត់នៃពាណិជ្ជកម្ម។ អ្នកអាចដាក់ពាក្យសុំមិនឱ្យមានការបោះផ្សាយជាសាធារណៈនូវព័ត៌មានសម្ងាត់ពាណិជ្ជកម្ម ដោយប្រើទម្រង់ពាក្យស្នើសុំដែលមានស្រាប់នៅក្នុងគេហទំព័ររបស់ក្រសួង។

| | | |
|---|---|---|
| ខ្ញុំទទួលយល់ព្រមថា ព័ត៌មានរៀបរាប់ខាងលើនឹងអាចដាក់ផ្សាយដោយសេរីនៅក្នុងគេហទំព័ររបស់ក្រសួងបាន។ | បាទ/ចាំ ☐ | ទេ ☐ |
| ខ្ញុំបានបំពេញ និងភ្ជាប់នូវពាក្យស្នើសុំឱ្យរក្សាទុកនូវព័ត៌មានសម្ងាត់ទាក់ទងនឹងពាណិជ្ជកម្ម។ | បាទ/ចាំ ☐ | ទេ ☐ |

## 9. ការយល់ព្រម

| | | |
|---|---|---|
| តើអ្នកយល់ព្រមទទួលការទាក់ទងបញ្ជូនឯកសារពាក់ព័ន្ធនឹងពាក្យស្នើសុំនេះ ព្រមទាំងអាជ្ញាប័ណ្ណនាពេលអនាគតតាមរយៈអាសយដ្ឋានអ៊ីម៉ែល ដែលអ្នកបានផ្ដល់ឱ្យខាងលើនេះឬទេ? | បាទ/ចាំ ☐ | ទេ ☐ |

## 10. សេចក្ដីប្រកាស

ⓘ បុគ្គលដែលមានសមត្ថកិច្ចចំពោះមុខច្បាប់ត្រូវចុះហត្ថលេខាក្នុងសេចក្ដីប្រកាសនេះ។ ដើម្បីទទួលបានអាជ្ញាប័ណ្ណដោយមានឈ្មោះនៃបុគ្គលនីមួយៗដែលជាដៃគូ ឬចូលរួមអាជីវកម្មនោះ ដៃគូនីមួយៗ ឬអ្នកចូលរួមអាជីវកម្មត្រូវចុះហត្ថលេខានៅក្នុងសេចក្ដីប្រកាសនេះ។

ខ្ញុំសូមប្រកាសអះអាងថា តាមការដឹងយល់របស់ខ្ញុំ ព័ត៌មានដែលផ្ដល់ជូនក្នុងពាក្យស្នើសុំនេះ ព្រមជាមួយនឹងឯកសារភ្ជាប់ គឺជាការពិត និងត្រឹមត្រូវ។

| | **អ្នកដាក់ពាក្យសុំ 1** | **អ្នកដាក់ពាក្យសុំ 2** |
|---|---|---|
| **ឈ្មោះ៖** | | |
| **តួនាទី/មុខងារ៖** | | |
| **ហត្ថលេខា៖** | | |
| **កាលបរិច្ឆេទ៖** | | |

## បញ្ជីផ្ទៀងផ្ទាត់អ្នកដាក់ពាក្យសុំ

ⓘ ចូរធ្វើការបញ្ជាក់ថា អ្នកបានបំពេញពាក្យស្នើសុំ រួមជាមួយភស្តុតាងពាក់ព័ន្ធទាំងឡាយដែលបានភ្ជាប់មកជាមួយ

<table>
<tr><td>បញ្ជាក់នូវចំនួនទំព័រនៃឯកសារភ្ជាប់ជាមួយនឹងពាក្យស្នើសុំនេះ</td><td></td></tr>
<tr><td>អ្នកមានសិទ្ធដាក់ពាក្យស្នើសុំ<br>• សំណួរ 1A៖ បានកំណត់នូវទីតាំងដីថាឋិតនៅក្នុងអតីតភូមិបាលគ្រប់គ្រងទឹកជនបទនៃក្រុងដារវិន ឬ<br>• សំណួរ 1B ៖ បានកំណត់នូវទីតាំងដីថាឋិតនៅក្នុងភូមិភាគ Adelaide River នៃភូមិបាលគ្រប់គ្រងទឹកជនបទនៃក្រុងដារវិន</td><td>☐<br>☐</td></tr>
<tr><td>ព័ត៌មានពិស្តាររបស់អ្នកដាក់ពាក្យសុំ<br>• សំណួរ 2 ៖ បានផ្តល់ព័ត៌មានពិស្តារនៃអ្នកដាក់ពាក្យសុំ ភ្ជាប់ជាមួយនឹងសម្រង់ព័ត៌មានអាជីវកម្ម ឬសម្រង់ព័ត៌មានក្រុមហ៊ុនពី ASIC ដែលមានឈ្មោះម្ចាស់ក្រុមហ៊ុន។ ប្រសិនបើមិនបានចុះបញ្ជីការទេ, ចូរផ្តល់ព័ត៌មានអំណះអំណាងដែលថា សកម្មភាពរបស់អ្នកមានលក្ខណៈពាណិជ្ជកម្ម។<br>• សំណួរ 3 ៖ បានផ្តល់ព័ត៌មានរបស់អ្នកធ្វើការទំនាក់ទំនងទី១ និងអ្នកធ្វើការទំនាក់ទំនងទី២។</td><td>☐<br>☐</td></tr>
<tr><td>ព័ត៌មានអំពីទីតាំងដី<br>• សំណួរ 4 ៖ បានផ្តល់ព័ត៌មាននៃអាសយដ្ឋានទីតាំងដីដែលធ្វើសកម្មភាពពាណិជ្ជកម្ម<br>• សំណួរ 5 ៖ ការប្រើប្រាស់ដីដោយស្របច្បាប់<br>  ○ បានភ្ជាប់មកជាមួយនូវច្បាប់ចម្លងនៃប័ណ្ណសម្គាល់ម្ចាស់កម្មសិទ្ធអចលនវត្ថុ ឬ<br>  ○ បានភ្ជាប់មកជាមួយនូវច្បាប់ចម្លងនៃកិច្ចសន្យាជួល ឬកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរអនុញ្ញាតឲ្យប្រើប្រាស់ទីតាំងដី។ កិច្ចសន្យាជួល ឬកិច្ចព្រមព្រៀង ឬត្រូវមានសរសេរពីការអនុញ្ញាតឱ្យស្នាក់នៅ និងការអនុញ្ញាតឱ្យធ្វើសកម្មភាពនានាទាក់ទងនឹងអាជ្ញាប័ណ្ណដែលបានស្នើសុំ។</td><td>☐<br>☐</td></tr>
<tr><td>សកម្មភាពពាណិជ្ជកម្ម<br>• សំណួរ 6 ៖ បានផ្តល់ព័ត៌មានពិស្តារនៃអាជីវកម្ម ឬសកម្មភាពនានាដែលបច្ចុប្បន្ននេះធ្វើឡើងជាផ្នែកនៃសកម្មភាពអាជីវកម្ម។<br>  ○ បានភ្ជាប់មកជាមួយនូវផែនទីពិស្តារនៃដី និងភស្តុតាងបញ្ជាក់ពីសកម្មភាពអាជីវកម្មដែលកំពុងដំណើរការ<br>  ○ បានភ្ជាប់ជាមួយនូវឯកសារភស្តុតាងនានាបញ្ជាក់ពីសកម្មភាពអាជីវកម្មដែលកំពុងដំណើរការ។</td><td>☐<br>☐<br>☐</td></tr>
<tr><td>ការប្រើប្រាស់ទឹកក្រោមដី និងហេដ្ឋារចនាសម្ព័ន្ធ ដើម្បីបូមយកទឹកមកប្រើ<br>• សំណួរ 7 ៖ បានផ្តល់ព័ត៌មានពិស្តារពីអណ្តូងខួងទាំងអស់ដែលបានប្រើ ដើម្បីបូមទឹក និងការប៉ាន់ប្រមាណពីបរិមាណទឹកប្រើប្រាស់ប្រចាំឆ្នាំ។</td><td>☐</td></tr>
<tr><td>ការទទួលស្គាល់និងយល់ព្រម<br>• សំណួរ 8 ៖ ការចុះបញ្ជីការសាធារណៈ និងព័ត៌មានសម្ងាត់នៃពាណិជ្ជកម្ម<br>• សំណួរ 9 ៖ ការយល់ព្រម<br>• សំណួរ 10 ៖ សេចក្តីប្រកាស</td><td>☐<br>☐<br>☐</td></tr>
</table>